# វេទិកាពលរដ្ឋ
# FORUM FOR THE PEOPLE

សហរដ្ឋអាមេរិក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២

## សេចក្តីថ្លែងការណ៍
## តុលាការត្រូវសើរើសំណុំរឿងក្តីអយុត្តិធម៌របស់លោក សុន ឆ័យ

**វេទិកាពលរដ្ឋ** សូមថ្កោលទោសការសម្រេចក្តីរបស់តុលាការរាជធានីភ្នំពេញ និងរដ្ឋាភិបាលនៃលោក **ហ៊ុន សែន** ប្រើលេសនយោបាយទុច្ចរិតជាប្រព័ន្ធ ទម្លាក់កំហុសយ៉ាងអយុត្តិធម៌ទៅលើរូបលោក **សុន ឆ័យ** អនុប្រធានគណបក្សភ្លើងទៀន ដោយប្រតិដ្ឋបទចោទ «បរិហារកេរ្តិ៍ជាសាធារណៈ» នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងការបោះឆ្នោតឃុំសង្កាត់ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២។

តាមផ្លូវច្បាប់ លោក **សុន ឆ័យ** មានសិទ្ធិពេញលេញស្របតាមរដ្ឋធម្មនុញ្ញ មាត្រា៣៥ និងមាត្រា៤១ «កថាខណ្ឌទី១» ក្នុងនាមជាអ្នកនយោបាយ ដែលមានភារកិច្ចអនុវត្តសិទ្ធិនយោបាយប្រកួតប្រជែងស្មើមុខគ្នា ជាមួយគណបក្សកាន់អំណាច និងគណបក្សផ្សេងៗទៀត។

**វេទិកាពលរដ្ឋ** សូមអំពាវនាវដល់តុលាការកម្ពុជា សើរើសំណុំរឿងក្តីយ៉ាងអយុត្តិធម៌របស់លោក **សុន ឆ័យ** នេះឡើងវិញ ដើម្បីឲ្យគាត់មានសិទ្ធិសេរីភាពពេញលេញក្នុងជីវភាពនយោបាយស្របច្បាប់។

**វេទិកាពលរដ្ឋ** សូមលើកទឹកចិត្តថ្នាក់ដឹកនាំ និងអ្នកគាំទ្រគណបក្សភ្លើងទៀន ហ៊ានចេញមុខតវ៉ាជាសាធារណៈ ទាមទារយុត្តិធម៌ជូនលោក **សុន ឆ័យ** ស្របតាមរដ្ឋធម្មនុញ្ញ មាត្រា៣៧ ស្តីពីសិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី។

**អនុប្រធានវេទិកាពលរដ្ឋ**

**ម៉ែន ណាត**

Address: 58 Poplar Street, Plains PA 18 705, USA